គណកម្មការពលករ
COMITE VIE OUVRIERE
ព្រះសហគមន៍កាតូលិកភ្នំពេញ
VICARIAT APOSTOLIQUE DE PHNOM PENH

សង្ខេបព័ត៌មាន
**9/2018**

## ប្រាក់ឈ្នួលគោលកម្មករសម្រាប់ឆ្នាំ២០១៩ នឹងត្រូវពិភាក្សាចាប់ពីថ្ងៃទី១០ ខែកញ្ញា

ភ្នំពេញ៖ គណៈកម្មការប្រឹក្សាការងារ នឹងចាប់ផ្តើមប្រជុំពិភាក្សាការចរចាប្រាក់ឈ្នួលគោលរបស់កម្មករវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើង ចាប់ពីថ្ងៃទី ១០ ខែកញ្ញា តទៅ។ ។ នេះបើតាមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

តាមរយៈកិច្ចប្រជុំមួយរបស់គណកម្មការប្រឹក្សាការងារ នៅថ្ងៃទី៣ ខែកញ្ញា ក្រុមការងារបច្ចេកទេសត្រីភាគីនឹងចាប់ផ្តើមប្រជុំពិភាក្សាអំពីប្រាក់ឈ្នួលគោលកម្មករ ចាប់ពីថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ២០១៨តទៅ។

ក្រុមការងារនេះមានសមាសភាពចំនួន ១៦រូប មកពីភាគីកម្មករនិយោជិត និយោជិត និយោជក និងភាគីរដ្ឋាភិបាល។

ក្រុមការងារនេះ នឹងប្រើប្រាស់យន្តការលក្ខណៈវិនិច្ឆ័យបែបសង្គម និងសេដ្ឋកិច្ចធ្វើជាមូលដ្ឋានក្នុងការពិភាក្សារបស់ខ្លួន៕

ថ្មីថ្មី 9/9/2018

## កម្មការិនីរោងចក្រ ១១នាក់បានការងារធ្វើវិញ ក្រោយមានការសម្របសម្រួល

ស្វាយរៀង៖ កម្មការិនីរោងចក្រ ១រូប ដែលមានផ្ទៃពោះ ៦ខែ និង១០នាក់ផ្សេងទៀត បានត្រលប់ចូលធ្វើការនៅរោងចក្រ យូលី អិនធើណេសិនណល(ខេមបូឌា) ហ្វាមិន ខូអិលធីឌីវិញហើយ បន្ទាប់ពីមានការសម្របសម្រួលពីមន្ទីរ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តស្វាយរៀងប្រាប់ពីភ្នំពេញប៉ុស្តិ៍ម្សិលមិញ។

លោក អ៊ូ សុខឿន បានថ្លែងថា បន្ទាប់ពីបានទទួលព័ត៌មាន មានកម្មការិនីម្នាក់ មានផ្ទៃពោះ ៦ខែ ត្រូវបានថ្នាក់ដឹកនាំក្រុមហ៊ុន ឲលោឈប់ពីការងារ។

លោកបន្តថា៖ “ រឿងដែលកម្មករ ដែលត្រូវក្រុមហ៊ុនបញ្ឈប់នេះ មិនមែនមានតែស្ត្រីពោះធំម្នាក់ទេ មានកម្មការិនីផ្សេងទៀតប្រមាណជា ១០នាក់ឯណោះ ហើយការបញ្ឈប់ពីការងារ គឺព្រោះតែពួកគាត់ប្រើប្រាស់ឯកសារមិនពិត។

លោកអះអាងថា៖ “ ខ្ញុំក៏បានទាក់ទងតាមទូរស័ព្ទ កុំទាន់បញ្ចប់កិច្ចសន្យា ដោយសន្យាដល់ពួកគាត់ឲបានធ្វើការងារបន្តទៀត។ ដោយខ្ញុំបានឲក្រុមហ៊ុននឹងធ្វើសំណើរទៅក្រសួងការងារ ដើម្បីស្នើសុំប្រើប្រាស់ពលកម្មវ័យក្មេង។ អញ្ចឹងទៅមិនមានខុសអីទៀតទេ ព្រោះច្បាប់ការងាររបស់យើង គេកំណត់ឲធ្វើការងារបានចាប់តាំងពីអាយុ ១៥ឆ្នាំឡើងទៅម្លេះ។

លោក ប៉ាវ ស៊ីណា ប្រធានសម្ព័ន្ធសហជីពចលនាកម្មករ (CUMW) បញ្ជាក់ឲដឹងថា ចំពោះកម្មករម្នាក់ ដែលមានផ្ទៃពោះនោះ គាត់បានចូលធ្វើការដោយមិនទាន់គ្រប់អាយុ ហើយខ្ចីឯកសារគេ ដើម្បីយកទៅដាក់ពាក្យធ្វើការងារ ដល់ពេលគេពិនិត្យឃើញគេតម្រូវឲកម្មករនោះ កែឯកសារឡើងវិញ។

លោកបន្តថា៖ “ ដល់ពេលទៅកែឯកសារឡើងវិញ គាត់នៅតែមិនទាន់គ្រប់អាយុដដែល។ អញ្ចឹងរោងចក្រគេមិនបានបណ្ដេញអីទេ គ្រាន់តែតម្រូវ ឲពួកគាត់ទៅរៀបចំឯកសារយ៉ាងម៉េច ដើម្បីឲត្រូវនឹងច្បាប់ការងារ”។

លោកស៊ីណាបានអះអាងថា៖ “ ឥលូវមកដល់ពេលនេះ យើងបានការពារគាត់ មិនឲក្រុមហ៊ុនបញ្ឈប់គាត់ទេ ហើយក្រុមហ៊ុនក៏មិនបញ្ឈប់គាត់ដែរ ពួកគាត់នៅធ្វើការធម្មតាទេ”។

ភ្នំពេញប៉ុស្ដ 9/9/2018

## ការចរចារដំឡើងប្រាក់ឈ្នួល នៅមានការខ្វែងគំនិតគ្នានៅឡើយ

ភ្នំពេញៈ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ សហជីព និងភាគីពាក់ព័ន្ធនៅខ្វែងគំនិតគ្នានៅឡើយចំពោះការតំឡើងប្រាក់ឈ្នួលអប្បបរមាដល់ផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើងសម្រាប់ឆ្នាំ២០១៩ ខណៈសហជីពលោកអាត់ ធន លើកយកសំណើរមកពិភាក្សាចំនួន ២១១,៩៥ ដុល្លារ ប៉ុន្តែក្រុមសហជីពដែលគាំទ្ររដ្ឋាភិបាល និងក្រសួងការងារមិនទាន់ឯកភាព។

ក្រុមការងារនេះដឹកនាំដោយលោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារ និងជាអនុប្រធានលេខាធិការដ្ឋានគណកម្មការប្រឹក្សាការងារ ដើម្បីពិភាក្សាកម្រិតបច្ចេកទេសដែលមានលក្ខណៈលម្អិត និងគ្រប់ជ្រុងជ្រោយដែលអាចទទួលយកបានពីគ្រប់ភាគី និងជាមូលដ្ឋានសម្រាប់គណកម្មការប្រឹក្សាការងារប្រជុំសម្រេច។

យ៉ាងណាក្តី លោក អាត់ ធន ប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកាត់ដេរកម្ពុជា បានថ្លែងថា កិច្ចចរចារនេះនៅមិនទាន់ចេញជាលទ្ធផលទេ ព្រោះភាគីទាំងអស់នៅបន្តសុំពេលវេលាបន្ថែមដើម្បីរកចំណុចរួមតែមួយ។

លោក បានបន្តថាក្នុងកិច្ចប្រជុំ ក្រុមសហជីពរបស់លោកបានដាក់សំណើរស្នើសុំដំឡើង ២១១,៩៤ ដុល្លារ ខណៈប្រាក់ឈ្នួលនៅឆ្នាំនេះមានតែ ១៧០ ដុល្លារ ប៉ុន្តែមន្ត្រីក្រសួងសុំតំឡើងតែ ៤ ភាគរយនៃប្រាក់ដែលមានស្រាប់គឺស្មើជាង ៧ ដុល្លារ។

លោក កាំង ម៉ូនីកា អគ្គលេខាធិការងសមាគមរោងចក្រកាត់ដេរកម្ពុជាបានថ្លែងថា ការជជែកគ្នានេះគឺក្នុងកិច្ចប្រជុំជាលើកដំបូង ហើយក៏មិនទាន់មានលទ្ធផលជាផ្លែផ្កាដែរ។

លោកបានបញ្ជាក់ថាៈ “ ភាគីទាំងអស់បានណាត់ជួបគ្នាម្តងទៀតនៅថ្ងៃទី ១៤ កញ្ញា ដើម្បីគំណត់តួលេខរួមមួយ ហើយយើងនឹងយកតួលេខរួមហ្នឹងទៅពិភាក្សាគ្នា និងដាក់សំណើរទៅថ្នាក់លើបន្តទៀត” ។

ភ្នំពេញប៉ុស្ត 11/9/2018

## ស្វែងយល់ពីច្បាប់ដំឡើងប្រាក់ឈ្នួលកម្មករ

ច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមារបស់កម្មករកាត់ដេរ និងឧស្សាហកម្មស្បែកជើងត្រូវបានអនុវត្ត ហើយកាលពីឆ្នាំទៅដែលកំណត់ចំនួន ១៧០ ដុល្លារ ហើយក្រុមការងារចម្រុះក៏បានប្រជុំពិភាក្សាគ្នាបន្តទៀតសម្រាប់ប្រាក់ឈ្នួលកម្មករក្នុងឆ្នាំ ២០១៩។

តើប្រាក់ឈ្នួលអប្បបរមាបច្ចុប្បន្នអាចទ្រទ្រង់ជីវភាពកម្មករបានសមរម្យដែរឬយ៉ាងណានោះ ភ្នំពេញប៉ុស្ដិ៍បានសម្ភាសន៍ជាមួយលោក អាត់ ធន ប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជាដូចខាងក្រោមៈ

ទាក់ទិននឹងប្រាក់ឈ្នួលអប្បបរមាបើលោកប្រៀបធៀបប្រាក់ខែកម្មករកាត់ដេរជាមួយតម្លៃទំនិញលើទីផ្សារតើយ៉ាងម៉េចដែរ?ចុះចំពោះ ប.ស.ស វិញគឺគាត់ទៅទីនោះនៅពេលដែលមានហានិភ័យហ្នឹងទេ ដូចជាការព្យាបាលជំងឺអីចឹងទៅ។

ប្រាក់ឈ្នួលអប្បបរមាត្រូវបានក្រសួងការងារអនុវត្តជិត ១ ឆ្នាំហើយនៅលើវិស័យកាត់ដេរសម្លៀកបំពាក់ និង ស្បែកជើង ហើយក៏បានចាប់ផ្តើមពិភាក្សាបន្តទៀតដែរសម្រាប់ឆ្នាំក្រោយ។ តើក្រសួង នឹងយកប្រាក់ដែលកំណត់ ១៧០ ដុល្លារជាគោលសម្រាប់ពិភាក្សាទៅថ្ងៃមុខទៀតឬយ៉ាងណា?

ក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈបានលើកឡើងថា ការចរចារប្រាក់ឈ្នួលអប្បបរមានៅឆ្នាំនេះគឺខាងក្រសួងយក ១៧០ ដុល្លារជាចំនួនប្រាក់គោល បានន័យថាក្រសួងនេះមិនបានយកបន្ទាត់ភាពក្រីក្រ ឬក៏ការសិក្សាស្រាវជ្រាវណាមួយមកផ្ទៀងផ្ទាត់ទេ។

ភ្នំពេញប៉ុស្ត 17/9/2018

## CDC អនុញ្ញាតក្រុមហ៊ុន៦ បើករោងចក្រកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង- កាបូប

ភ្នំពេញៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) បានអនុញ្ញាតឲ្យក្រុមហ៊ុនចំនួន ៦ បើករោងចក្រកាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើង- កាបូប នៅក្នុងទីតាំងផ្សេងគ្នានៅកម្ពុជា។ ក្រុមហ៊ុន ទាំង៦នេះ មានទុនវិនិយោគសរុប ២៧,៨ លានដុល្លារ ព្រមទាំងបង្កើតការងារបានជិត៧ពាន់កន្លែងជូនប្រជាពលរដ្ឋ។ នេះបើតាមប្រកាសរបស់ CDC នៅថ្ងៃទី ១៨ ខែកញ្ញា។

CDC បានឲ្យដឹងថា ក្រុមហ៊ុនទាំង៦នោះ មានក្រុមហ៊ុន DE XIANG GRAMENT និងក្រុមហ៊ុន YANXIN THREAD LACE មានទីតាំងនៅខណ្ឌពោធិជ័យ រាជធានីភ្នំពេញ។ ដោយក្រុមហ៊ុន DE XIANG GRAMENT គ្រោងបង្កើតរោងចក្រកាត់ដេរ សម្លៀកបំពាក់។ ក្រុមហ៊ុន YANXIN THREAD LACE គម្រោងបង្កើតរោងចក្រខារអំបោះ ផលិតខ្សែស្បែកជើង និងគ្រឿងបន្សំស្បែកជើង។ ក្រុមហ៊ុនទាំងពីរនេះ មានទុនវិនិយោគជាង៦លានដុល្លារ ដោយអាចបង្កើតការងារបានជាង១ពាន់កន្លែង។

ក្រុមហ៊ុន HIGH HOPE CAMBODIA ) APPAREL MANUFACTURING និងក្រុមហ៊ុន AYC GARMENT FACTORY គ្រោងបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់នៅក្នុងស្រុកអង្គស្នួល ខេត្តកណ្ដាល ដោយមានទុនវិនិយោគ៨,៥៦លានដុល្លារ និងអាចបង្កើតការងារបាន២ពាន់កន្លែង។

ក្រុមហ៊ុន FENGFAN ( CAMBODIA ) គ្រោងបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ នៅភូមិកណ្ដឹងធំ ឃុំកណ្ដឹង ស្រុកបាទី ខេត្តតាកែវ មានទុនវិនិយោគប្រមាណ ៧,០៥ លានដុល្លារ និងបង្កើតការងារបានជាង៣ពាន់កន្លែង។

ដោយឡែកក្រុមហ៊ុន GOODNEWS PACKAGING TECHNOLOGY គ្រោងបង្កើតរោងចក្រផលិតគ្រឿងបន្សំស្បែកជើង កាបូប និងសម្លៀកបំពាក់ នៅស្រុកគងពិសី ខេត្តកំពង់ស្ពឺ មានទុនវិនិយោគ ៦,១០ លានដុល្លារ ដោយអាចបង្កើតការងារបាន២៧០កន្លែង។ នេះបើតាម CDC៕

ថ្មីថ្មី 18/9/2018

## ក្រសួងការងារ ចេញប្រកាសអោយកម្មករកាត់ដេរបើកប្រាក់ឈ្នួល២ដងក្នុង១ខែពីឆ្នាំ ២០១៩

ចាប់ពីខែមករា ឆ្នាំ២០១៩ កម្មករ ឬនិយោជិតដែលធ្វើការក្នុងវិស័យកាត់ដេរអាចបើកប្រាក់ឈ្នួលបានពីរដងក្នុង១ខែ។ កម្មករអាចបើកប្រាក់ឈ្នួលលើកទីមួយបាន៥០ភាគរយនៃប្រាក់សរុប នៅចុងសប្តាហ៍ទី២ និងបើកលើកទី២នៅចុងសប្តាហ៍ទី៤ ដោយទទួលបានប្រាក់ឈ្នួលដែលនៅសល់ ៥០ភាគរយទៀតរួមជាមួយប្រាក់អត្ថប្រយោជន៍ផ្សេងៗ។

ការអនុវត្តបែបនេះនឹងធ្វើឡើងជារៀងរាល់ខែ។ យោងតាមប្រកាសស្តីពីការបើកប្រាក់ឈ្នួលជូននិយោជិតរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ម្ចាស់រោងចក្រសហគ្រាសទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារត្រូវតែរៀបចំការបើកប្រាក់ឈ្នួលអោយកម្មករពីរដងក្នុង១ខែ។

ចំពោះបទបញ្ញត្តិទាំងឡាយដែលផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍៕

ថ្មីថ្មី 22/9/2018

**RFA** 30/9/18